នស/រកត/០៥០៦/២០៧

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបង្កើត **គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា** ។

**មាត្រា២** : ត្រូវបានតែងតាំងសមាសភាពគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជាដូចមានរាយព្រះនាមដូចខាងក្រោម :

១. សម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា។

២. សម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះធម្មលិខិត ព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា។

៣. សម្តេចព្រះវន្ន័រត **អ៊ំ លឹមហេង** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះពោធិវង្ស ព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា។

៤. ព្រះឃោសធម្ម **ណយ ច្រឹក** ព្រះរាជាគណៈថ្នាក់ទោ ជាសម្តេចព្រះវន្ន័រត ព្រះរាជាគណៈថ្នាក់ឯក ព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា២ :** ព្រះរាជក្រឹតនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៦០៥.២១៦

លេខ: ១៩៨ ច.ល

**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង
រាជធានីភ្នំពេញ.ថ្ងៃទី៤ ខែឧសភា ឆ្នាំ

រាជធានីភ្នំពេញ.ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**